នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jul-2011, 10:01
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលឆ្លើយតបទៅនឹង ចម្លើយតបរបស់មេធាវីការពារក្ដី ស្ដីពីការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |
| | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី: | មេធាវីការពារក្ដីជនជាប់ចោទ: |
| | | លោក សុន អរុណ |

| | |
|---|---|
| លោក ពេជ អង្គ | លោក Michiel PESTMAN |
| Elisabeth SIMONNEAU FORT | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

# សំណើ

១. ដោយអនុលោមតាមវិធាន៣៩.៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាសូមស្នើដោយគោរព សុំពន្យារពេល ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1] ("សេចក្តីសន្និដ្ឋានរបស់ កសព")។

២. នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានពន្យារកាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបនានា ទៅនឹងសេចក្តីសន្និដ្ឋានរបស់ កសព រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ហើយបានណែនាំថា ការឆ្លើយតបណាមួយដោយសហព្រះរាជអាជ្ញា ត្រូវដាក់នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១១[2]។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានទទួលការជូនដំណឹងមួយស្តីពីចម្លើយតបរបស់មេធាវីការពារក្តី នួន ជា ដែលបានដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស នៅថ្ងៃនោះ[3]។ យ៉ាងណាក៏ដោយ ពួកគាត់មិនបានទទួលនូវការជូនដំណឹងស្តីពីចម្លើយតបរបស់ អៀង ធីរិទ្ធ ទេ ដែលបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ជាភាសាអង់គ្លេសតែប៉ុណ្ណោះ រហូតដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១[4]។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានទទួលនូវការជូនដំណឹងមួយស្តីពីការដាក់ជូនទាំងឡាយដូចតទៅនេះគឺ ការជូនដំណឹងទាំងអស់ដែលបានដាក់ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ មាន៖ ចម្លើយតបដោយក្រុមមេធាវីការពារក្តី អៀង សារី ជាភាសាអង់គ្លេសតែប៉ុណ្ណោះ[5], ចម្លើយតបដោយ ខៀវ សំផន ជាភាសាខ្មែរ និងភាសាបារាំង[6], និងចម្លើយតបដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ជាភាសាអង់គ្លេសតែប៉ុណ្ណោះ។

៣. មាត្រា៨.៥ នៃសេចក្តីណែនាំអនុវត្តក្នុងការដាក់ឯកសារចែងថា "ពេលវេលាកំណត់ត្រូវរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់

---

[1] **E96**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃ១៥ មិថុនា ២០១១។

[2] **E107**, សេចក្តីសម្រេចលើសំណើសុំពន្យារពេល, ថ្ងៃទី៧ កក្កដា ២០១១ ។

[3] **E96/1**, សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ទាក់ទងទៅនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី, ថ្ងៃទី២១ កក្កដា ២០១១ ។

[4] **E96/2**, ចម្លើយតបរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", ថ្ងៃទី២២ កក្កដា ២០១១ ។

[5] **E96/3**, ចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២២ កក្កដា ២០១១ ។

[6] **E96/4**, សេចក្តីសង្កេតតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹង ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី, ថ្ងៃទី២២ កក្កដា ២០១១ ។

អវតក"។ នៅពេលដាក់ជូនសំណើនេះ គឺនៅសល់ពេលចំនួនប្រាំមួយថ្ងៃប៉ុណ្ណោះ រហូតដល់កាលបរិច្ឆេទកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញានៅមិនទាន់បានទទួលការជូនដំណឹងជាភាសាខ្មែរ ស្តីពីចម្លើយតបចំនួនបីក្នុងចម្លើយតបចំនួនប្រាំដែលសហព្រះរាជអាជ្ញាមានបំណងនឹងធ្វើការឆ្លើយតប។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ពេលច្រើនជាងមួយខែសម្រាប់ដាក់ចម្លើយតបទាំងអស់នេះ។

៤. ដើម្បីជាប្រយោជន៍នៃការលើកកម្ពស់ប្រសិទ្ធភាពតុលាការ សហព្រះរាជអាជ្ញាសូមដាក់ចម្លើយតបរួមមួយ ទៅនឹងចម្លើយតបទាំងនេះ (សរុបមានចំនួនជាង៦០ទំព័រ ជាភាសាអង់គ្លេស/បារាំង)។ ប៉ុន្តែ ដូចបានបញ្ជាក់ជូនពីខាងលើ ដោយមានការលើកលែងចំពោះការដាក់ឯកសាររបស់ នួន ជា គ្រប់ចម្លើយតបទាំងអស់ ត្រូវបានប្រគល់ជូនដោយមានការពន្យារពេលរហូតដល់ បី ឬ បួនថ្ងៃ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គេមិនអាចរៀបចំចម្លើយតបរួមមួយប្រកបដោយប្រសិទ្ធភាពបានឡើយ ដោយហេតុថា ចម្លើយតបនានាត្រូវបានចែកចាយយឺតពេល ហើយចម្លើយតបចំនួនបី ក្នុងចំណោមចម្លើយតបទាំងនេះ មិនទាន់មានជាភាសាខ្មែរនៅឡើយ។

៥. បញ្ហានានាដែលបានលើកឡើងនៅក្នុងសារណាទាំងនេះ មានលក្ខណៈស្មុគស្មាញ និងតម្រូវឱ្យមានការពិភាក្សាសម្រេចយ៉ាងប្រុងប្រយ័ត្ន។ ប៉ុន្តែបើសិនការដាក់ឯកសារមិនមានជាភាសាខ្មែរ អ្នកច្បាប់និយាយភាសាខ្មែរនៅការិយាល័យសហព្រះរាជអាជ្ញា មិនស្ថិតក្នុងគោលជំហរមួយដើម្បីចូលរួមឱ្យបានពេញលេញនៅក្នុងការរៀបចំចម្លើយតប ឬការឆ្លើយតបនានាបានទេ។

៦. ដោយសារមូលហេតុខាងលើទាំងនេះហើយ ទើបសហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង ពន្យារពេលវេលាកំណត់សម្រាប់ការដាក់ចម្លើយតបរួមមួយ ដល់ប្រាំពីរថ្ងៃ ចាប់ពីថ្ងៃដែលអាចរកបាននូវការបកប្រែជាភាសាខ្មែរនៃចម្លើយតបទាំងអស់។ ការពន្យារពេលនេះនឹងជួយសម្រួលដល់ការអនុវត្តដំណើរការនីតិវិធីឱ្យបានឆាប់ផង និងការប្រើប្រាស់ធនធាននៃការបកប្រែប្រកបដោយប្រសិទ្ធភាពផង (តាមរយៈការដាក់ចម្លើយតបតែមួយ) ក្នុងខណៈពេលដែលផ្តល់នូវលទ្ធភាពដល់អ្នកច្បាប់និយាយភាសាខ្មែរនៅការិយាល័យនេះ បានរួមចំណែកយ៉ាងមានប្រសិទ្ធភាពដើម្បីបង្កើតបាននូវរូបរាងនៃចម្លើយតប ដែលជាបញ្ហានីតិវិធីសំខាន់មួយ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |